# អនុក្រឹត្យ លេខ ៥៤ អនក្រ.បក
## ស្តីពីការ កែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ ចុះថ្ងៃទី២៧ ខែ មិនា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមសំណូមពរការងារចាំបាច់ របស់រាជរដ្ឋាភិបាល

### សំរេច

មាត្រា ១ .- កែសំរួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ហៅកាត់ “ គ ជ គ ម “ ឬ NCDM “ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-សម្តេចនាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-រដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៤-រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៦-រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧-ឥស្សរជនជាន់ខ្ពស់ មួយរូប ជាសមាជិកកិត្តិយសអមគណៈកម្មាធិការ ទទួលបន្ទុកបេសកកម្មពិសេសសំរបសំរួល | សមាជិក |
| ៨-រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ៩-តំណាងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១០-រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

ក្នុងករណីក្រសួងមានសហរដ្ឋមន្ត្រីដឹកនាំ សហរដ្ឋមន្ត្រីនោះត្រូវធ្វើជាអនុប្រធាន ឬសមាជិក នៃគណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា ២ .- ក្រសួង និង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមសហការជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទៅតាមតំរូវការចាំបាច់ ។

មាត្រា ៣ .- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវធ្វើជាដៃគូយ៉ាងសំខាន់ ជាមួយសមាគមន៍ជាតិកាកបាទក្រហមកម្ពុជា ក្នុងការជួយសង្គ្រោះ នៅពេលមានគ្រោះមហន្តរាយ ។

មាត្រា ៤ .- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ដាក់ចេញគោលការណ៍ចាំបាច់ ទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។
- ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី ស្តីពីវិធានការបង្ការ ត្រៀមរៀបចំលក្ខណៈទប់ទល់ កាត់បន្ថយគ្រោះមហន្តរាយ ឆ្លើយតប សង្គ្រោះបន្ទាន់ និង ស្តារឡើងវិញក្រោយពេលកើតហេតុ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងប្រទេសជិតខាងនានា ។
-ណែនាំពីសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ និង ស្ថាប័នដទៃទៀត ។
-ធ្វើសំណើទៅរាជរដ្ឋាភិបាល ស្តីពីតំរូវការ និងការប្រើប្រាស់ធនធាន ដូចជាមូលនិធិ សំភារៈមធ្យោបាយ ប្រេងឥន្ធនៈ និងសំភារៈចាំបាច់ដទៃទៀត សំរាប់ចុះអន្តរាគមន៍ និងផ្តល់ជំនួយដល់ការខូចខាតក្នុងពេលមានគ្រោះមហន្តរាយ ។
-សំរបសំរួលការងារជាមួយអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្នុងនិងក្រៅប្រទេស និងជាមួយក្រសួងស្ថាប័ន ព្រមទាំងសមាគម សប្បុរសជននានា ដើម្បីចូលរួមសហការក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។
- អំពាវនាវដល់ស្ថាប័នជាតិដទៃទៀត ដើម្បីផ្តល់អ្នកជំនួយការក្នុងសកម្មភាពនេះ ។

មាត្រា ៥ .- សមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន ។

មាត្រា ៦ .- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវកោះប្រជុំសាមញ្ញ យ៉ាងតិច៦ខែម្តង ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិ អាចកោះប្រជុំវិសាមញ្ញ ។

មាត្រា ៧ .- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាស្ថាប័នជាតិមួយ ចំណុះរាជរដ្ឋាភិបាល មានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិធ្វើលេខាធិការ និង ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល លើការងារកសាងគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា ៨ .- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មាន :

៨-១ : អគ្គលេខាធិការដ្ឋាន ដំណើរការជាប្រចាំ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ។

៨-២ : នាយកដ្ឋាន៤ចំណុះអគ្គលេខាធិការដ្ឋានរួមមាន :

- នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច
- នាយកដ្ឋានសំរបសំរួលសង្គ្រោះបន្ទាន់ និង ស្តារឡើងវិញ
- នាយកដ្ឋានត្រៀមរៀបចំសង្គ្រោះបន្ទាន់ និង បណ្តុះបណ្តាល
- នាយកដ្ឋានរុករក និង សង្គ្រោះ ឧប្បត្តិហេតុយន្តហោះ-នាវា

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានជាជំនួយការ ព្រមទាំងមានការិយាល័យចំណុះមួយចំនួនទៀត ។

៨-៣ : នៅតាមខេត្ត-ក្រុង មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - អភិបាលខេត្ត-ក្រុង | ជាប្រធាន |
| - អភិបាលរងខេត្ត-ក្រុង | ជាអនុប្រធាន |
| - ប្រធានមន្ទីរជុំវិញខេត្ត-ក្រុង | ជាសមាជិក |

៨-៤ : នៅតាមស្រុក-ខ័ណ្ឌ មានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - អភិបាលស្រុក-ខ័ណ្ឌ | ជាប្រធាន |
| - អភិបាលរងស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យនីមួយៗក្នុងស្រុក ខ័ណ្ឌ | ជាសមាជិក |

អង្គការលេខរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ៩ .- តួនាទី និង ភារកិច្ចរបស់អង្គភាពនៅក្នុងមាត្រា ៨ មានចែងដូចតទៅ :

៩-១ : អគ្គលេខាធិការដ្ឋាន

-រៀបចំសំណើសុំការយល់ព្រមពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការចេញសេចក្តីប្រកាសភាពអាសន្នថ្នាក់ជាតិនៅតាមតំបន់ដែលទទួលការខូចខាតធំធេង និងភាពអាសន្ន ថ្នាក់ខេត្ត-ក្រុង ដែលស្នើឡើងដោយអភិបាលខេត្ត-ក្រុង ។

-កសាងផែនការសកម្មភាពត្រៀមរៀបចំប្រតិបត្តិការសង្គ្រោះបន្ទាន់ វិធានការទប់ស្កាត់ និងការរៀបចំផែនការស្តារឡើងវិញ ដាក់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយសុំការយល់ព្រម ដើម្បីយកមកអនុវត្ត ។

- ប្រមូលផ្តុំគណៈកម្មការវិទ្យាសាស្ត្រ និង បច្ចេកទេសដែលមានការចូលរួមពីមន្ត្រីជំនាញ មកពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិនានា សំដៅកំណត់គោលនយោបាយជាតិ ទំរង់បែបបទ កសាងផែនការត្រួតពិនិត្យ ផ្នែកបច្ចេកទេសចំពោះសកម្មភាពរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្នុងការអនុវត្តវិធីសង្គ្រោះបន្ទាន់ ត្រៀមលក្ខណៈទប់ទល់គ្រោះមហន្តរាយព្រមទាំងលើកសំណើសុំធ្វើវិសោធនកម្មផ្លាស់ប្តូរគោលនយោបាយគ្រប់គ្រងគ្រោះមហន្តរាយ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស ។

-ធ្វើអធិការកិច្ចលើវិធីការចំណាយ កំណត់អាទិភាពនៃការចែករំលែកមូលនិធិ សេវាកម្មសំភារៈ បរិក្ខារ និង គ្រឿងផ្គត់ផ្គង់ក្នុងការជួយសង្គ្រោះ ។

-ណែនាំផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ស្តីពីការអនុវត្តន៍ គោលនយោបាយគ្រប់គ្រងគ្រោះមហន្តរាយ ។

-ធ្វើរបាយការណ៍ទៀងទាត់ ស្តីពីសភាពការណ៍ និងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយជូន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**៩-២ : នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច :**

- ទទួលខុសត្រូវផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងការផ្គត់ផ្គង់
- ទទួលខុសត្រូវការងាររៀបចំ កសាងសំណុំលិខិត ឯកសារផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់ និង អនាម័យ ។
- គ្រប់គ្រងមន្ត្រី បុគ្គលិក ដោះស្រាយប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបានកំណត់ដោយរាជរដ្ឋាភិបាល ។
- រៀបចំគំរោងថវិកា គំរោងសំភារៈបរិក្ខារ និងមធ្យោបាយការងារផ្សេងៗ ។
- ទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ និងភ្នាក់ងារហិរញ្ញវត្ថុរបស់អង្គការផ្តល់ជំនួយនានា ក្នុង ការប្រើប្រាស់ថវិកា ។
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ និងរាល់ការចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន ។

**៩-៣ : នាយកដ្ឋានសំរបសំរួលសង្គ្រោះបន្ទាន់ និង ស្តារឡើងវិញ**

- រៀបចំបង្កើតឡើងនូវរចនាសម្ព័ន្ធបញ្ជាការ ក្នុងសកម្មភាពសង្គ្រោះបន្ទាន់ស្របទៅតាមគោលនយោបាយជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅពេលទទួលបានពត៌មានព្យាករណ៍ ស្តីពីលទ្ធភាពកើត

ឡើងនៃគ្រោះមហន្តរាយ រួចជូនពត៌មានដល់ស្ថាប័នពាក់ព័ន្ធគណៈកម្មការវិទ្យាសាស្ត្រ និង បច្ចេកទេសអង្គការជាតិ និងអង្គការអន្តរជាតិនានា ព្រមទាំងរាយការណ៍ជូនអគ្គលេខាធិការជ្រាប និង ចាត់វិធានការអនុវត្ត ។

- សំរបសំរួលរៀបចំការងារសន្តិសុខនៅក្នុងតំបន់មានគ្រោះមហន្តរាយ ចំពោះបុគ្គលិកសង្គ្រោះបន្ទាន់ជនរងគ្រោះ និងមន្ត្រីជាន់ខ្ពស់ចុះសួរសុខទុក្ខ ។

- ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គទូត និងគ្រួសារជនរងគ្រោះ ។

- កំណត់ដំណើរការសកម្មភាពតាមសំណូមពរ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់

- ផ្តល់យោបល់ជូនអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំធ្វើសេចក្តីប្រកាសភាពអាសន្ននៅតាមតំបន់ដែលអាចទទួលការប៉ះពាល់ និងស្នើសុំផ្តល់មូលនិធិ ដើម្បីសង្គ្រោះបន្ទាន់ ។

- រៀបចំផែនការសកម្មភាពក្នុងការទប់ស្កាត់ កាត់បន្ថយគ្រោះថ្នាក់ និងការស្តារឡើងវិញ ក្រោយពេលគ្រោះមហន្តរាយ ។

### ៩-៤ : នាយកដ្ឋានត្រៀមរៀបចំសង្គ្រោះបន្ទាន់ និង បណ្តុះបណ្តាល

- ត្រៀមរៀបចំមូលដ្ឋាន សំភារៈ គ្រឿងផ្គត់ផ្គង់ផ្សេងៗសំរាប់ធ្វើការងារសង្គ្រោះបន្ទាន់ ក្នុងគ្រាមានគ្រោះអាសន្ន ។

- ផ្តល់យោបល់ជូនស្ថាប័នពាក់ព័ន្ធ ស្តីពីការអនុវត្តន៍ច្បាប់សាងសង់ដែលអាចជាមុខសញ្ញាគ្រោះថ្នាក់នៃ គ្រោះមហន្តរាយ ។

- កសាងកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ដែលបំពេញការងារគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងកម្មវិធីអប់រំផ្សព្វផ្សាយជាសាធារណៈ នៅក្នុងសហគមន៍ ។

- កសាងព្រឹត្តិប័ត្រពត៌មាន ស្តីពីគ្រោះមហន្តរាយផ្សេងៗ ។

- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធក្នុងការទទួលពត៌មាននិងទិន្នន័យផ្សេងៗ ស្តីពីការព្យាករណ៍គ្រោះមហន្តរាយ

### ៩-៥ : នាយកដ្ឋានរុករក និង សង្គ្រោះឧប្បត្តិហេតុយន្តហោះ-នាវា

- សំរបសំរួលបញ្ជូនពត៌មានពីយន្តហោះបាត់ខ្លួន ឬយឺតដំណើររយៈពេលយូរ ទៅរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល ដើម្បីផ្តួចផ្តើមសកម្មភាពស្របទៅតាមនីតិវិធីដែលបានរៀបចំឡើង ។

- បញ្ជូនពត៌មានស្តីពីឧប្បត្តិហេតុយន្តហោះ-នាវា និងស្នើសុំគោលការណ៍អនុវត្តបទបញ្ជា និងការណែនាំពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយទាក់ទងនឹងការសំរបសំរួល រុករកនិងសង្គ្រោះ

- ប្រកាសជាផ្លូវការពីទីកន្លែងកើតឧប្បត្តិហេតុយន្តហោះ-នាវា នៅពេលព័ត៌មានជាក់លាក់ ត្រូវបានផ្ទៀងផ្ទាត់ ។

- លើកសំណើជូនអគ្គលេខាធិការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ក្នុងការប្រើប្រាស់មធ្យោបាយ និង កំលាំងក្រុមរុករក និង សង្គ្រោះ ។

- ក្នុងពេលប្រតិបត្តិការរុករក និង សង្គ្រោះតាមផ្លូវគោក ផ្លូវអាកាស លើសមុទ្រ ក្រុមរុករកនិងសង្គ្រោះ ត្រូវសំរបសំរួលការងារជាមួយកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរដែនដីនៅ ទីកន្លែងកើតហេតុ ។

- សំរបសំរួលជាមួយប្រទេសជិតខាង ដើម្បីរួមសហការដោះស្រាយការងាររុករក និង សង្គ្រោះ ស្របទៅតាមកិច្ចព្រមព្រៀង ស្តីអំពីការសំរបសំរួលរុករក និង សង្គ្រោះ ។

- សំរបសំរួលជាមួយមជ្ឈមណ្ឌលសំរបសំរួលសង្គ្រោះ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលត្រូវបានកំណត់ជាទីតាំងកណ្តាលសំរាប់សំរបសំរួលបេសកកម្មរុករក និង សង្គ្រោះ ។

- ការអនុវត្តន៍ការងាររុករក និងសង្គ្រោះឧប្បត្តិហេតុយន្តហោះ-នាវា ត្រូវអនុលោមទៅតាមឧបសម្ព័ន្ធទី១២ នៃអនុសញ្ញាអាកាសចរស៊ីវិលអន្តរជាតិ ។

## ៩-៦ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង

- អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

- រៀបចំធ្វើការណែនាំ និងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ។

- ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំពោះសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា ការជួយឧបត្ថម្ភរបស់អង្គការជាតិ និងអន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមរៀបចំ សង្គ្រោះបន្ទាន់ និង ស្តារឡើងវិញ ។

- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការខូចខាត និងធ្វើសំណើសុំឧបត្ថម្ភថវិកា សំភារៈបរិក្ខារ មធ្យោបាយ និងកំលាំងអន្តរាគមន៍សំរាប់ដោះស្រាយក្នុងពេលមានគ្រោះមហន្តរាយ ។

- អនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញបច្ចេកទេសដល់មន្ត្រីបំរើការងារ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តន៍កម្មវិធីអប់រំ ជាសាធារណៈនៅក្នុងសហគមន៍ ។

គណៈកម្មាធិការនេះមានរចនាសម្ព័ន្ធគ្រប់គ្រងដូចថ្នាក់ជាតិដែរ ហើយត្រូវបង្កើតទីស្នាក់ការមួយដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តន៍ការងារអចិន្ត្រៃយ៍របស់ខ្លួន ។

### ៩-៧ : គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខណ្ឌ

- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។
- ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង អំពីស្ថានការណ៍ថ្មីៗ
- ជ្រើសរើសមន្ត្រី ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ ឬ ខេត្ត-ក្រុង ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- រៀបចំ និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជនអំពីគ្រោះមហន្តរាយ
- បញ្ជូនរបាយការណ៍ ស្តីពីសេចក្តីត្រូវការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តក្រុង ស្តីពីការខូចខាត និងតម្រូវការផ្សេងៗ ។
- ដឹកនាំប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ រួមមានជំនួយសង្គ្រោះ ការជម្លៀស ការផ្តល់ទីជំរក និងការផ្តល់ជំនួយស្តារនីតិភាព ។
- បញ្ជូនរបាយការណ៍សរុប ស្តីពីប្រតិបត្តិការជំនួយសង្គ្រោះទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ។

មាត្រា១០ .- ក្របខ័ណ្ឌមន្ត្រីរាជការ បុគ្គលិក របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រួមមានមន្ត្រីរាជការ បុគ្គលិកបញ្ជូនមកពីក្រសួងស្ថាប័ន ស្របទៅតាមតម្រូវការការងារជាក់ស្តែង របស់អគ្គលេខាធិការដ្ឋាន ។

មាត្រា ១១ .- អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានសិទ្ធិបង្កើតគណនេយ្យមួយ និងប្រើត្រាសម្រាប់ឡែករបស់ខ្លួន ។

មាត្រា ១២ .- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

មាត្រា ១៣ .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយបានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

